90

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

47/6

តុលាការកំពូល

# ក្នុងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៤៦

ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣

សាលដីកា

លេខ: ១៥៧

ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម | [redacted] | ជាប្រធាន |
| ២-លោក | [redacted] | ជាចៅក្រម |
| ៣-លោក | [redacted] | ជាចៅក្រម |
| ៤-លោក | [redacted] | ជាចៅក្រម |
| ៥-លោក | [redacted] | ជាចៅក្រម |

ក្រឡាបញ្ជី

លោកស្រី [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១០៣ "ក្រប" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៤៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់តុលាការកំពូល។

<u>ពីបទ:</u> ការចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ដោយមានស្ថានទម្ងន់ (ក្នុងគោលដៅជំរិតទ្រព្យសម្បត្តិ) និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត្តិ ប្រព្រឹត្តនៅមុខសាកលវិទ្យាល័យជាតិគ្រប់គ្រង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ កាលពីថ្ងៃទី២៧ និង២៨ ខែមករា ឆ្នាំ២០១១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៥៣ ២៥៤ និងមាត្រា២៩០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណណាត "ជាម្ចាស់បណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរគ្មាន ទីលំនៅមុនពេលចាប់ខ្លួនផ្លូវ៣៦ (សូទី) សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ



Scanned by CamScanner

រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] នៅលីវ។ បច្ចុប្បន្នជាប់ពន្ធនាគារព្រៃសម១។

មេធាវីលោក [redacted] គ្រុយ

-ដើមបណ្ដឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] សោភា "ជាចុងបណ្ដឹងសាទុក្ខ" ភេទស្រី អាយុ១៨ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៦៣E₀ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។

-កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ វេលាម៉ោង១៣.៣០នាទី ដោយមានគម្រោងរៀបចំជាមុនឈ្មោ [redacted] វណ្ណណាត ហៅ ដេត បានធ្វើសកម្មភាពបើកទ្វាររថយន្តចូលភ្ជង់ដោយអាវុធខ្លីពុំស្គាល់ម៉ាកលើឈ្មោះ [redacted]សោភា ហៅ ប៊ី ភេទស្រី អាយុ១៨ឆ្នាំ ខណៈពេលជនរងគ្រោះកំពុងអង្គុយក្នុងរថយន្តម៉ាកកាមរីសេរី២០០២ ពណ៌ទឹកប្រាក់ ផ្លាកលេខភ្នំពេញ 2M-8315 នៅមុំសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងសង្កាត់វត្តភ្នំ និងបង្ខំឲ្យជនរងគ្រោះបើករថយន្តចេញពីចំណុចកើតហេតុ និងបានប្ដូរ បើកដោយខ្លួនឯងឆ្ពោះទៅខេត្តព្រះសីហនុ ដោយបានបង្ខាំងទុកជនរងគ្រោះនៅបន្ទប់លេខ១១២ សណ្ឋាគារខ្សាច់មាស ដោយចងដៃជើង និងយកស្កុតបិទមាត់ជនរងគ្រោះ ហើយបានទូរស័ព្ទទាក់ទងម្ដាយជនរងគ្រោះទារប្រាក់ចំនួន៣០០.០០០ដុល្លាអាមេរិក (សាមសិបម៉ឺនដុល្លាអាមេរិក)។ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ជនល្មើសបានទូរស័ព្ទទៅម្ដាយជនរងគ្រោះម្ដងទៀត និងបានទាមទារប្រាក់ត្រឹម១៥០.០០០ដុល្លាអាមេរិក (ដប់ប្រាំម៉ឺនដុល្លាអាមេរិក) ដោយកំណត់ត្រឹមម៉ោង១៤ នៅផ្សារ City Mall ភ្នំពេញ ហើយចងដៃចងជើង និងបិតស្កុត បិទមាត់ជនរងគ្រោះ ដោយជិះរថយន្តឈ្នួលមកភ្នំពេញ ដើម្បីទទួលប្រាក់ ពេលមកជួបម្ដាយជនរងគ្រោះក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួននៅពេលកំពុងធ្វើសកម្មភាព ចំណែកជនរងគ្រោះបានរើចំណង រួចក៏ទៅប្ដឹងសមត្ថកិច្ច។ ក្រោយពីឃាត់ខ្លួនឈ្មោះ [redacted] វណ្ណណាត សមត្ថកិច្ចបានរកឃើញអាវុធមួយដើមដែលធ្វើសកម្មភាព។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា:

មានភស្តុតាង និងពិរុទ្ធភាពលើឈ្មោ [redacted] វណ្ណណាត ភេទប្រុស អាយុ២៩ឆ្នាំ ពីបទ ការចាប់ និងបង្ខាំងដោយខុសច្បាប់ ដោយមានស្ថានទម្ងន់ទោស (ក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ) និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ និងថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្ដន្ទាទោសតាមមាត្រា២៥៣ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១១៤ "ក្រ៦ជ" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសំរេច:

Scanned by CamScanner

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វណ្ណណាត ហៅ ឆេត ភេទប្រុស អាយុ២៩ឆ្នាំ (មានសាវតាជាតិខាងឪ) ដាក់ពន្ធនាគារកំណត់១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) និងពិន័យជាប្រាក់ចំនួន១.០០០.០០០រៀល (មួយលានរៀល) ពីបទ ការចាប់ និងបង្ខាំងមនុស្សដោយខុសច្បាប់ ដោយមានស្ថានទម្ងន់ (ក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ) និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧ និង២៨ ខែមករា ឆ្នាំ២០១១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៥៣, ២៥៤ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២-វត្ថុតាងចាប់យករួមមាន:

ក/-កាំភ្លើងខ្លីមួយដើមមិនស្គាល់ម៉ាក បង់មួយមានចំនួនពីរគ្រាប់ ស្កត់សំរាប់បិតមាត់ចំនួន២បន្ទះ ខ្សែចំណងរូត (ខ្សែសៀល) មិនប្រើចំនួន៣១ខ្សែ និងប្រើរួចចំនួន៤ខ្សែ រឹបអូស និងបំផ្លាញចោល។

ខ/-ទូរស័ព្ទ១គ្រឿងម៉ាក NOKIA C6 មានស៊ីម, ស្បែកជើង១គូរ កាបូបក្រណាត់ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ពេលសាលក្រមនេះចូលជាស្ថាពរ។

៣-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណណាត សងជម្ងឺចិត្តចំនួន១០.០០០.០០០ (ដប់លានរៀល) ឲ្យទៅជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សោភា ទាមទារលើសពីនេះបដិសេធចោល។

៤-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦៩៤ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] វណ្ណណាត ប្តឹងមិនសុខចិត្តសាលក្រមព្រហ្មទណ្ឌលេខ១១៤ "ក្រ៦ជ" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: សូមឲ្យសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១០៣ "ក្រ II" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយរួមនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១១៤ "ក្រVIជ" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបាន។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី។

៤-សាលដីកានេះជំនុំជំរះ និងជាសាធារណៈ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្ដឹងសាទុក្ខលេខ៣១២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២ របស់លោក [redacted]ុយ មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted]វណ្ណណាត ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១០៣ "ក្រII" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: ចម្លើយរបស់ជនរងគ្រោះ និងម្ដាយរបស់ជនរងគ្រោះមានភាពស៊ីសង្វាក់គ្នា បើពិនិត្យអំពីស្ថានភាពរបស់ជនជាប់ចោទ និងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ គឺមានធាតុផ្សំគ្រប់គ្រាន់កំណត់ជាបទល្មើស ការឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ដោយមានស្ថានទម្ងន់ "ក្នុងគោលដៅជំរិតទ្រព្យសម្បត្តិ" និងកាន់កាប់អាវុធខុសច្បាប់ ដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅមុខសាកលវិទ្យាល័យជាតិគ្រប់គ្រង បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា២៥៣ មាត្រា២៥៤ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ។ សូមឱ្យតុលាការពិចារណាអំពីកម្រិត នៃការផ្តន្ទាទោសជាថ្មី តាមខ្លឹមសារនៃមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ។

អាស្រ័យដូចបានជំរាបជូនខាងលើ និងការពារផលប្រយោជន៍ច្បាប់ និងផលប្រយោជន៍យុត្តិធម៌ចំពោះជនរងគ្រោះ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជំរះសំរេចដូចការយល់ឃើញខាងលើ។

-បានស្ដាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted]វណ្ណណាត នាពេលសវនាការថា: មូលហេតុខ្ញុំប្ដឹងសាទុក្ខមកតុលាការកំពូលនេះ គឺមិនត្រឹមត្រូវទេ ព្រោះនេះជារឿងឆាកល្ខោន ដើម្បីការពារកិត្តិយសរបស់ឈ្មោះ [redacted]សោភា តែម្នាក់គត់។ ចំពោះសំភារៈដូចជាអាវុធ ជារបស់ខ្ញុំដែលរកឃើញនៅក្នុងផ្ទះខ្ញុំ ជាអាវុធចាស់គ្មានម៉ាកទេ សូម្បីតែប៉ូលីសក៏មិនស្គាល់ម៉ាកដែល ព្រោះជារបស់ចាស់ ដែលមិនអាចប្រើបានទេ។ ខាងប៉ូលីសបានបង្ខំសួរខ្ញុំពីរឿងអាវុធ ដោយមានយកភ្លើងអគ្គិសនីយកមក អុជកខ្ញុំ ដើម្បីបង្ខំឱ្យខ្ញុំឆ្លើយថា មានកាំភ្លើង។

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោក [redacted] ក្រុយ មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted]វណ្ណណាត នាពេលសវនាការថា: ក្រោយពីបានស្ដាប់ចម្លើយរបស់កូនក្ដីខ្ញុំរួចមក ដោយយោង

Scanned by CamScanner

តាមអង្គហេតុ គឺកូនក្តីធ្វើរាល់សកម្មភាព គឺដើម្បីក្នុងគោលបំណងរក្សា កិត្តិយស និងកេរ្តិ៍ឈ្មោះដល់ជនរងគ្រោះឈ្មោះ[redacted] សោភា តែប៉ុណ្ណោះ។

ចំណែកការផ្តល់ទំនាក់ទំនង និងភស្តុតាងក្នុងបន្ទប់សណ្ឋាគារ សាក្សីបានឃើញអ្នកទាំង២នាក់ដើរចូលក្នុងបន្ទប់ជាលក្ខណៈប្តីប្រពន្ធ ដោយគ្មានការបង្ខិតបង្ខំ និងគំរាមកំហែង តាមរូបភាពណាមួយឡើយ។ ដោយសារតែសកម្មភាពប្លែកៗទាំងនេះ និងដោយសារតែកូនក្តីខ្ញុំបាទមានបំណងនិងឆន្ទៈគោរពទៅតាមពាក្យសម្តីរបស់ភាគីខាងស្រី ពីព្រោះដើម្បីបិទបាំងកេរ្តិ៍ឈ្មោះ និងកិត្តិយសរបស់នាងជាធំ។ សូម្បីតែចម្លើយរបស់ភាគីខាងស្រីផ្ទាល់ក៏មិនបានបញ្ជាក់ថា កូនក្តីរបស់ខ្ញុំមិនបានប្រើអំពើហិង្សា និងប្រព្រឹត្តនូវទង្វើមិនគប្បីចំពោះនាងឡើយ។ យោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញបានចែងថា: វិមតិសង្ស័យត្រូវបានជាផលប្រយោជន៍របស់ជនជាប់ចោទ។ ហើយគ្រប់សកម្មភាពទាំងអស់ គឺសុទ្ធតែស្ថិតនៅក្នុងភាពវិមតិសង្ស័យ និងពុំមានចេតនាប្រព្រឹត្តបទល្មើសនោះទេ។ ដោយសង្កេតឃើញថា មាត្រា១៣៧ ក្រមព្រហ្មទណ្ឌបានវែកញែក កូនក្តីគឺស្ថិតក្នុងគោលការណ៍ស្រួបទោស ចោទប្រកាន់បទល្មើសតែ១ប៉ុណ្ណោះ ។ តែនៅតុលាការថ្នាក់ក្រោមសំរេចចោទបទល្មើស២។

សំណូមពរ: សូមក្រុមប្រឹក្សាជំនុំជំរះ បង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: សូមរក្សាសេចក្តីសន្និដ្ឋាននៅដដែល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនត្រូវចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីអោយជនត្រូវចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣១២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ឈ្មោះ[redacted]ណ្ណណាត ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបាន។

-យល់ឃើញថា ការដែលសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍សំរេចប្រកាសទោស និងផ្តន្ទាទោសលើជនត្រូវចោទឈ្មោះ[redacted] វណ្ណណាត ពីបទ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ក្នុងគោលដៅជំរិតទារប្រាក់ និងកាន់កាប់អាវុធដោយខុសច្បាប់ មានសំរាងហេតុ និង



Scanned by CamScanner

៥ 47/1

សេចក្តីសំរេចផ្ទុយគ្នា ពីព្រោះថា តាមចម្លើយសាក្សីឈ្មោះ [redacted] វិសាល ជាអ្នកទទួលភ្ញៀវនៅសណ្ឋាគារខ្សាច់មាស និង [redacted] សារ៉េត ជាអ្នកទទួលភ្ញៀវនៅបឹងកាឡូ អូរឈើទាល ពុំបានបញ្ជាក់អំពីហេតុនៃអំពើល្មើសទេ តែបញ្ជាក់អំពីការស្រុះស្រួលគ្នាមកជួលស្នាក់នៅតែប៉ុណ្ណោះ។

-យល់ឃើញថា: រឿងក្តីនេះគប្បីសាលាឧទ្ធរណ៍ធ្វើការស៊ើបសួរអង្កេតឡើងវិញ។

-យល់ឃើញថា សាលដីកាសភាព្រហ្មទណ្ឌលេខ១០៣ "ក្រII" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះទាស់នឹងគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ៣១២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] វណ្ណណាត។

២-បដិសេធសាលដីកាសភាព្រហ្មទណ្ឌលេខ១០៣ "ក្រII" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៤៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ឆ្នាំ២០១៣

ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]